# ស្ថាប័នសម្របសម្រួលពាក្យបណ្តឹងសម្រាប់តំបន់ឆ្នេរជាប់ឈូងសមុទ្រ
# សេចក្តីសង្ខេបប្រតិបត្តិ
# ថ្ងៃទី18 ខែមេសា ឆ្នាំ2011

ខណៈដែលឧប្បត្តិហេតុផ្ទុះរចនាសម្ព័ន្ធខួងប្រេង និងធ្លាយប្រេងលើផ្ទៃទឹកជ្រៅ (Deepwater Horizon) ខិតជិតដល់គំរប់ខួបមួយឆ្នាំ ស្ថាប័នសម្របសម្រួលបណ្តឹងទាមទារសំណងសម្រាប់តំបន់ឆ្នេរជាប់ឈូងសមុទ្រ ("GCCF") បន្តធ្វើការត្រួតពិនិត្យ និងបង់ប្រាក់សំណងជូនអ្នកទាមទារសំណងរាប់ពាន់នាក់ –ទាំងបុគ្គល និងអាជីវកម្ម– ដែលបានទទួលរងការខូចខាត ដោយសារការធ្លាយប្រេង។ ស្ថាប័ន GCCF បានចាប់ផ្តើមប្រតិបត្តិការ នៅថ្ងៃទី23 ខែសីហា ឆ្នាំ 2010 ដោយទទួលគ្រប់គ្រងដំណើរការត្រួតពិនិត្យបណ្តឹងទាមទារសំណងពីក្រុមហ៊ុន BP (ដែលបង់សំណងសរុបចំនួន $398 លានដល់អ្នកទាមទារសំណងប្រហែល 50,000 នាក់ ក្នុងរយៈពេល 4 ខែ ពីថ្ងៃទី20 ខែមេសា ដល់ថ្ងៃទី23 ខែសីហា ឆ្នាំ2010)។

ស្ថាប័ន GCCF បន្តដាក់បុគ្គលិកនៅការិយាល័យទទួលបណ្តឹងទាមទារសំណងចំនួន 35 កន្លែងក្នុងរដ្ឋ 5 (គឺរដ្ឋ Alabama រដ្ឋ Florida រដ្ឋ Louisiana រដ្ឋ Mississippi និងរដ្ឋ Texas)។ ស្ថាបន័ GCCF ជួលបុគ្គលិកប្រហែល 3,200 នាក់ ក្នុងនោះមាន អ្នកវាយតម្លៃបណ្តឹងទាមទារសំណង អ្នកជំនាញទទួលបណ្តឹងទាមទារសំណង អ្នកទទួលទូរស័ព្ទ គណនេយ្យករ មេធាវី អ្នកគ្រប់គ្រងរដ្ឋបាល និងបុគ្គលិកជួយកិច្ចការដទៃទៀត។ ស្ថាប័ន GCCF នឹងបន្តត្រួតពិនិត្យពាក្យបណ្តឹងទាមទារសំណង រហូតដល់ថ្ងៃទី 22 ខែសីហា ឆ្នាំ2013។

ស្ថិតិ និងព័ត៌មានខាងក្រោមបង្ហាញពីទំហំការងារ ដែលមិនធ្លាប់មានពីមុនមក ដែលស្ថាប័ន GCCF ប្រឈម និងពីជោគជ័យរបស់ស្ថាប័ន ក្នុងរយៈពេល 9 ខែកន្លងមកនេះ ក្នុងការត្រួតពិនិត្យបណ្តឹងទាមទារសំណង ដែលបុគ្គល និងអាជីវកម្មទទួលរងផលប៉ះពាល់ ដោយសារការធ្លាយប្រេង បានដាក់មកស្ថាប័ន ៖

1) ចាប់តាំងពីថ្ងៃទី 23 ខែសីហា ឆ្នាំ2010 មក ស្ថាប័ន GCCF បានទទួលពាក្យបណ្តឹងទាមទារសំណងប្រហែល 857,000 ពីបុគ្គល និងអាជីវកម្មជាង 504,000។

2) ចាប់តាំងពីថ្ងៃទី 23 ខែសីហា ឆ្នាំ2010 មក ស្ថាប័ន GCCF បានយល់ព្រមលើបណ្តឹងទាមទារសំណងប្រហែល 300,000 ដែលពាក់ព័ន្ធនឹងបុគ្គល និងអាជីវកម្ម ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ប្រហែល 180,000 នាក់។ ក្នុងអំឡុងរយៈពេលសំណងបង់ជាមុនសម្រាប់តម្រូវការបន្ទាន់ ("EAP") ពីថ្ងៃទី 23 ខែសីហា ដល់ថ្ងៃទី 23 ខែវិច្ឆិកា ឆ្នាំ2010 ស្ថាប័ន GCCF បានបង់សំណងប្រហែល $2.6 ពាន់លានដល់អ្នកទាមទារសំណងចំនួន 169,035 នាក់។ ចាប់តាំងពីពេលនោះមក ស្ថាប័ន GCCF បានបង់សំណងបន្ថែមជាង $1.2 ពាន់លានដល់អ្នកទាមទារសំណងបង់ជាមុនសម្រាប់តម្រូវការបន្ទាន់ជាច្រើននាក់ ដែលបានដាក់ពាក្យបណ្តឹងទាមទារសំណងជាលើកទី 1 បន្ទាប់ពីផុតរយៈពេល EAP ។

3) ចាប់តាំងពីរយៈពេល EAP បានបញ្ចប់នៅថ្ងៃទី 23 ខែវិច្ឆិកា ឆ្នាំ2010 មក ស្ថាប័ន GCCF បានទទួលពាក្យបណ្តឹងទាមទារសំណាងចំនួនប្រហែល 278,000 ហើយបានត្រួតពិនិត្យបណ្តឹងទាមទារសំណាងទាំងអស់ដែលបានដាក់មកស្ថាប័នបានប្រហែល 72%។ បណ្តឹងទាមទារសំណាងត្រូវបាន "ត្រួតពិនិត្យ" នៅពេលស្ថាប័ន GCCF បានលើកសំណើប្រាក់សំណាង (ដែលអ្នកទាមទារសំណាងមានរយៈពេល 90 ថ្ងៃដើម្បីឆ្លើយតប) នៅពេលស្ថាប័ន GCCF បង់ប្រាក់សំណាង នៅពេល ស្ថាប័ន GCCF បានផ្ញើសេចក្តីជូនដំណឹងទៅអ្នកទាមទារសំណាងអំពីការខ្វះខាតភស្តុតាង និងឯកសារដែលដាក់មកបញ្ជាក់បណ្តឹងទាមទារសំណាង ឬនៅពេលស្ថាប័ន GCCF ផ្ញើលិខិតទៅអ្នកទាមទារសំណាង ដែលបដិសេធចោលនូវបណ្តឹងទាមទារសំណាង ដោយផ្អែកលើការរកឃើញដោយស្ថាប័ន GCCF ថា អ្នកទាមទារសំណាងគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានសំណាងឡើយ។

4) ចាប់តាំងពីថ្ងៃទី23 ខែសីហា ឆ្នាំ2010 សំណាងលើបណ្តឹងទាមទារសំណាង ត្រូវបានបែងចែក ដូចខាងក្រោម ៖

a. ប្រាក់សំណាងបង់ជាមុនសម្រាប់តម្រូវការបន្ទាន់ – បុគ្គល និងអាជីវកម្មប្រហែល 169,000 បានទទួលសំណាងបង់ជាមុនសម្រាប់តម្រូវការបន្ទាន់ សម្រាប់រយៈពេលរហូតដល់ 6 ខែ ដោយពុំមានលក្ខខណ្ឌតម្រូវឲ្យអ្នកទាមទារសំណាងទាំងនេះលះបង់សិទ្ធិប្តឹង ឬលះបង់សិទ្ធិផ្លូវច្បាប់ដទៃទៀតឡើយ។ សំណាងបង់ជាមុនសម្រាប់តម្រូវការបន្ទាន់មានចំនួន $2.6 ពាន់លាន ។

b. សំណាងបង់ភ្លាម– អ្នកទាមទារសំណាងចំនួន 110,163 (បុគ្គលចំនួន 85,501 នាក់ និងអាជីវកម្ម 24,662) បានដាក់និងទទួលយកសំណាងបង់ភ្លាមចំនួន $5,000 ចំពោះបុគ្គលនិង $25,000 ចំពោះអាជីវកម្ម ដោយពុំមានលក្ខខណ្ឌណាមួយដែលតម្រូវឲ្យអ្នកទាមទារសំណាងទាំងនេះដាក់ភស្តុតាងបន្ថែម ដែលបញ្ជាក់ពីការខាតបង់របស់ខ្លួនឡើយ។ ជម្រើសនេះមានអត្ថប្រយោជន៍ចំពោះអ្នកទាមទារសំណាងដែលបានទទួលសំណាងសមស្របរួចហើយ តាមរយៈកម្មវិធីសំណាងបង់ជាមុនសម្រាប់តម្រូវការបន្ទាន់ ឬដែលមិនអាចបញ្ជាក់ភស្តុតាងពីការខូចខាតបន្ថែមទៀតដែលបណ្តាលមកពីការធ្លាយប្រេង។ អ្នកទាមទារសំណាង ដែលទទួលយកជម្រើសប្រាក់សំណាងបង់ភ្លាមនេះ លះបង់សិទ្ធិទាមទារសំណាងបន្ថែមពីស្ថាប័ន GCCF ឬដាក់ពាក្យបណ្តឹងទាមទារសំណាងដទៃទៀតចំពោះការខាតបង់ ឬការខូចខាត ដែលបណ្តាលមកពីការធ្លាយប្រេង។ សំណាង់បង់ភ្លាមរបស់ស្ថាប័ន GCCF នេះដែលបានបង់រហូតមកដល់ពេលនេះ មានចំនួនសរុប $998,680,000។

c. សំណាងចុងក្រោយ– ក្នុងរយៈពេល 8 សប្តាហ៍កន្លងមកនេះ អ្នកទាមទារសំណាងចំនួន 16,281 ( បុគ្គលចំនួន 15,250 នាក់និងអាជីវកម្មចំនួន 1,031) បានទទួលយកសំណើសំណាងចុងក្រោយពីស្ថាប័ន GCCF។ លើសពីនេះ GCCF បានធ្វើសំណើសំណាងចុងក្រោយ បន្ថែមប្រហែល 16,600

ដែលអ្នកទាមទារសំណងមានរយៈពេល 90 ថ្ងៃដើម្បីទទួលយក ឬបដិសេធ។ អ្នកទាមទារសំណងដែលទទួលយកជម្រើសនេះ លះបង់សិទ្ធិទាមទារសំណងពីស្ថាប័ន GCCF ឬដាក់ពាក្យបណ្តឹងទាមទារសំណងដទៃទៀតចំពោះការខាតបង់ ឬការខូចខាតដែលបណ្តាលមកពីការធ្លាយប្រេង។ សំណងចុងក្រោយរបស់ស្ថាប័ន GCCF ទាំងនេះដែលបានបង់រហូតមកដល់ពេលនេះ មានចំនួនសរុប $222,183,102។

d. សំណងបណ្តោះអាសន្ន– ក្នុងរយៈពេល 8 សប្តាហ៍កន្លងមកនេះ អ្នកទាមទារសំណងចំនួន 6,902 (បុគ្គលចំនួន 5,690 នាក់ និងអាជីវកម្មចំនួន 1,212) បានទទួលយកសំណងបណ្តោះអាសន្នពីស្ថាប័ន GCCF។ អ្នកទាមទារសំណងដែលទទួលយកសំណងបណ្តោះអាសន្ន មិនលះបង់សិទ្ធិទាមទារសំណងពី GCCF ហើយអាចទាមទារសំណងបន្ថែមពីស្ថាប័ន GCCF បាន ក្នុងត្រីមាសនីមួយៗ ប្រសិនបើអ្នកទាមទារសំណងអាចមានភស្តុតាងបញ្ជាក់ពីការខូចខាត ដែលបណ្តាលមកពីការធ្លាយប្រេងក្នុងអំឡុងត្រីមាសមុន។ សំណងបណ្តោះអាសន្នរបស់ស្ថាប័ន GCCF នេះមានចំនួនសរុប $78,691,137។

អ្នកទាមទារសំណងនីមួយៗ – ទោះជាបុគ្គល ឬអាជីវកម្មក្តី អាចជ្រើសយកដោយស្ម័គ្រចិត្តជម្រើសមួយក្នុងចំណោមជម្រើសទាំងបីខាងលើ (សំណងបង់ភ្លាម សំណងចុងក្រោយ សំណងបណ្តោះអាសន្ន)។ ស្ថាប័នGCCF ពុំប្រកាន់ជំហរអំពីថាតើជម្រើសមួយណាល្អសម្រាប់អ្នកទាមទារសំណងណាម្នាក់ឡើយ។ នេះពឹងផ្អែកលើស្ថានការណ៍នៃពាក្យបណ្តឹងទាមទារសំណងនីមួយៗ និងសេចក្តីសម្រេចដោយស្ម័គ្រចិត្តដោយអ្នកទាមទារសំណងថាតើជម្រើសមួយណាជាជម្រើសល្អ។ នេះជាសេចក្តីសម្រេចរបស់អ្នកទាមទារសំណងទាំងស្រុង។

នៅគំរប់ខួបឆ្នាំទី 1 នៃឧប្បត្តិហេតុផ្ទុះរចនាសម្ព័ន្ធខួងប្រេង និងការធ្លាយប្រេង ស្ថាប័ន GCCF សង្កត់ធ្ងន់លើចំណុចបន្ថែម ដូចខាងក្រោម ដែលត្រូវបានលើកយកមកជជែកវែកញែក ក្នុងរយៈពេល 9 ខែកន្លងទៅ៖

1) 1) អ្នកទាមទារសំណងទាំងឡាយនៅស្ថាប័ន GCCF ដែលជឿជាក់ថាស្ថាប័ន GCCF មានកំហុសក្នុងការកំណត់របស់ស្ថាប័ន ទាក់ទងនឹងលក្ខណៈសម្បត្តិ ឬការគណនាការខូចខាត មានជម្រើសដាក់ពាក្យបណ្តឹងទៅ ឆ្មាំងឈ្វងសមុទ្រសហរដ្ឋអាមេរិក (United States Coast Guard) សម្រាប់ការត្រួតពិនិត្យដោយឯករាជ្យ អនុលោមតាមច្បាប់ស្តីពីការបំពុលបរិស្ថានដោយប្រេង (OPA)។ រហូតមកដល់ពេលនេះ ឆ្មាំឈ្វងសមុទ្របានសម្រេចសេចក្តីក្នុង 574 ករណី។ <u>គ្មានករណីណាមួយដែលឆ្មាំឈ្វងសមុទ្ររកឃើញខុសពីការរកឃើញរបស់ស្ថាប័ន GCCF ទាក់ទងនឹងលក្ខណៈសម្បត្តិ ឬក៏កំណត់ថា ប្រាក់សំណងត្រូវបង់បន្ថែមទៅឲ្យអ្នកទាមទារ ពីលើសំណងដែលស្ថាប័ន GCCF បានបង់ទៅឲ្យអ្នកទាមទារសំណងនោះទេ។</u>

2) អ្នកទាមទារសំណងទាំងឡាយ ដែលជ្រើសយកជម្រើសសំណងចុងក្រោយ នឹងទទួលបានប្រាក់សំណងពីរដងនៃការខាតបង់ជាក់ស្តែងក្នុងឆ្នាំ 2010 ដែលមានឯកសារភស្តុតាងបញ្ជាក់ (បួនដងនៃការខាតបង់ជាក់ស្តែងក្នុងឆ្នាំ 2010 ដែលមានឯកសារភស្តុតាងបញ្ជាក់ ចំពោះអ្នកនេសាទ

និងអ្នកកែឆ្នៃអ៊ុយស្ទ័រ) ដកនឹងចំនួនប្រាក់ណាមួយ ដែលបានទទួលរួចហើយពីស្ថាប័ន GCCF ឬពីក្រុមហ៊ុន BP។ រូបមន្តនៃការខូចខាតអនាគតនេះផ្អែកលើគំនិតយោបល់របស់អ្នកជំនាញ ដែល GCCF ទទួលបាន ហើយបានសម្រេចយករូបមន្តនេះ បន្ទាប់ពីរាល់ភាគីពាក់ព័ន្ធទាំងអស់បានផ្តល់ជាយោបល់ជាសាធារណៈលើរូបមន្តដែលស្នើឡើងនេះ។ អ្នករិះគន់ភាគច្រើនដែលផ្តល់យោបល់លើរូបមន្តនេះ គិតថា វាមិនផ្តល់សំណងច្រើនគ្រប់គ្រាន់នោះទេ។ ក្រុមហ៊ុន BP បានផ្តល់យោបល់ជាសាធារណៈថា វាផ្តល់សំណងច្រើនពេកហើយ។ ស្ថាប័ន GCCF រក្សាសិទ្ធិកែប្រែរូបមន្តគណនាការខូតខាតនាថ្ងៃអនាគតរបស់ខ្លួន ប្រសិនបើកើតមានព្រឹត្តការណ៍ក្រោយមក ដូចការផានា។ រូបមន្តនេះផ្អែកលើ<u>ការព្យាករណ៍សមហេតុផល --ទោះមិនប្រាកដក៏ដោយ – ទាក់ទងនឹងអនាគតនៃឈូងសមុទ្រ និងពេល វេលាវើបឡើងវិញពេញលេញដែលបានព្យាករណ៍ទុក។</u> អ្នកទាមទារណាមួយក៏ដោយ ដែលជឿថា រូបមន្តនេះមិនពិចារណាពីភាពប្រែប្រួលនាអនាគតនោះ អាចជ្រើសរើសយកជម្រើសសំណងបណ្តោះអាសន្ន ដែលអនុញ្ញាតឲ្យដាក់ពាក្យបណ្តឹងជាត្រីមាស សម្រាប់ការខាតបង់ជាក់ស្តែង ដែលមានឯកសារភស្តុតាងបញ្ជាក់ ដែលនេះនឹងពន្យារពេលដាក់ពាក្យបណ្តឹងទាមទារសំណងចុងក្រោយ រហូតដល់ថ្ងៃអនាគត។

3) មានការពិភាក្សាជាសាធារណៈខ្លះទាក់ទងនឹងភាពខុសគ្នា រវាងការខូចខាតរបស់អ្នកទាមទារសំណង និងចំនួនប្រាក់សំណងដែលបានគណនា និងបង់សងជាក់ស្តែងដោយស្ថាប័ន GCCF។ ប៉ុន្តែ ភាពខុសគ្នារវាងចំនួនស្នើសុំ និងចំនួនបង់សង មិនមែនជាប្រធានបទដ៏មានផ្លែផ្កានៃការពិភាក្សានោះទេ។ ចំនួនដែលស្នើសុំដោយអ្នកទាមទារសំណង ជាញឹកញាប់ពុំមានទំនាក់ទំនងសមហេតុផលទៅនឹងការខូចខាតជាក់ស្តែង ដែលបានបញ្ជាក់ដោយភស្តុតាងនោះទេ។ ក្នុងករណីមួយ អ្នកទាមទារសំណងដាក់បណ្តឹងទាមទារសំណងទាំងអស់ $20 ពាន់លាន ចំណែកឯក្នុងករណីមួយផ្សេងទៀត អ្នកទាមទារសំណងទាមទារ $10 ពាន់លាន។ ជាទូទៅ ចំនួនស្នើសុំដោយអ្នកទាមទារសំណងជាច្រើននាក់ មិនសមាមាត្រនឹងការខូចខាតដែលបានបញ្ជាក់ភស្តុតាងជាក់ស្តែងនោះទេ ក្នុងឯកសារពាក្យបណ្តឹងដែលអ្នកទាមទារសំណងដាក់មកស្ថាប័ន GCCF។ ដូច្នេះ ភាពខុសគ្នារវាងចំនួនទាមទារ និងចំនួនបង់សង មិនមែនជាប៉ារ៉ាម៉ែត្រវាយតម្លៃលើវឌ្ឍនភាពនោះទេ។

4) ស្ថាប័ន GCCF បានពង្រីក និងពង្រឹងបុគ្គលិក នៅការិយាល័យទទួលបណ្តឹងទាមទារសំណងក្នុងស្រុកទាំង 35 កន្លែងរបស់ខ្លួន នៅតំបន់ឈូងសមុទ្រ ដែលជាការឆ្លើយតបទៅនឹងការរិះគន់ថា ការិយាល័យក្នុងស្រុកទាំងនេះពុំមានឆ្លើយសំណួរអ្នកទាមទារសំណងបានគ្រប់គ្រាន់អំពីស្ថានភាពនៃពាក្យបណ្តឹងទាមទារសំណងរបស់ពួកគេ ឬអំពីថាតើគណនាការខូចខាតដោយរបៀបណា។ ការិយាល័យទទួលបណ្តឹងទាមទារសំណងទាំងនេះបច្ចុប្បន្នមានគណនេយ្យករ អ្នកវាយតម្លៃបណ្តឹងទាមទារសំណង បុគ្គលិកប្រព័ន្ធ និងបុគ្គលិកទាក់ទងក្នុងស្រុកពីក្រុមមេធាវីនៅតំបន់ឈូងសមុទ្រ និងក្រុមហ៊ុនគ្រប់គ្រងបណ្តឹងទាមទារសំណង ដែលជួលឲ្យជួបជាមួយនឹងអ្នកទាមទារសំណងម្នាក់ៗ ដើម្បីពន្យល់ពីដំណើរការរបស់ស្ថាប័ន GCCF។

បុគ្គលិកទាំងនេះអាចជួបជាមួយនឹងអ្នកទាមទារសំណងម្នាក់ៗ និងជួយផ្ទាល់ ដែលអ្នកទាមទារសំណងចង់បាន។

5) ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីលើកកម្ពស់តម្លាភាពនៃដំណើរការត្រួតពិនិត្យពាក្យបណ្ដឹងទាមទារសំណង GCCF បានចុះផ្សាយនូវសំណើរនៃវិធានចុងក្រោយគ្រប់គ្រងលើជម្រើសប្រាក់សំណង លក្ខណៈវិនិច្ឆ័យលក្ខណៈសម្បត្តិ និងភស្តុតាងបញ្ជាក់ (Proposed Final Rule Governing Payment Options Eligibility and Substantiation Criteria) នៅលើវែបសាយរបស់ស្ថាប័ន GCCF ដើម្បីសាធារណៈជនផ្តល់ជាយោបល់។ បន្ទាប់ពីពិនិត្យយោបល់ពីសាធារណៈជនទាំងអស់រួចមក ស្ថាប័ន GCCF បានប្រកាសវិធានចុងក្រោយរបស់ខ្លួន នៅថ្ងៃទី18 ខែកុម្ភៈ ឆ្នាំ2011 ដែលមាននៅលើវេបសាយរបស់ស្ថាប័ន GCCF។ វិធានចុងក្រោយទាំងនេះមានលំអិតពីវិធីសាស្រ្តដែលស្ថាប័ន GCCF ប្រើដើម្បីកំណត់ពីលក្ខណៈសម្បត្តិ និងគណនាការខូចខាត។ លើសពីនេះ វិធានចុងក្រោយក៏មានចែងឲ្យស្ថាប័ន GCCF ឆ្លើយតបទៅអ្នកទាមទារសំណង ដោយបញ្ជាក់លំអិតពីមូលហេតុជាក់លាក់ ដែលបណ្ដឹងទាមទារសំណងពុំមានលក្ខណៈសម្បត្តិ ឬខ្វះភស្តុតាងដែលចាំបាច់។

ដំណើរការត្រួតពិនិត្យបណ្ដឹងទាមទារសំណងរបស់ស្ថាប័ន GCCF ជាកិច្ចខិតប្រឹងប្រែងជាពិសេស មិនធ្លាប់មានពីមុនមក ដើម្បីបង់សងអ្នកទាមទារសំណងរាប់សែននាក់ ដែលមានសិទ្ធិទទួលសំណង និងបានទទួលរងការខូចខាតផ្នែកហិរញ្ញវត្ថុ ដោយសារការផ្ទុះរចនាសម្ព័ន្ធខួងប្រេងលើផ្ទៃទឹកជ្រៅ (Deepwater Horizon) និងការធ្លាយប្រេង។ បរិមាណ និងភាពស្មុគស្មាញនៃបណ្ដឹងទាមទារសំណងជាបញ្ហាប្រឈមចំពោះប្រសិទ្ធិភាព និងភាពយុត្តិធម៌នៃដំណើរការត្រួតពិនិត្យបណ្ដឹងទាមទារសំណង។ ស្ថាប័នGCCF កំពុងសម្រេចនូវគោលបំណង ដែលបានកំណត់ដោយរដ្ឋាភិបាល និងក្រុមហ៊ុន BP ក្នុងការបង្កើតកម្មវិធីបង់សំណង ដើម្បីសងជនរងគ្រោះនៃគ្រោះមហន្តរាយ។ ស្ថាប័ន GCCF នឹងបន្តធ្វើការកែតម្រូវ ដែលចាំបាច់ ដើម្បីពន្លឿនដំណោះស្រាយ លើកកម្ពស់តម្លាភាព និងភាពស៊ីសង្វាក់នៃដំណើរការត្រួតពិនិត្យបណ្ដឹងទាមទារសំណង។